GREATER LOWELL TECHNICAL HIGH SCHOOL

250 PAWTUCKET BOULEVARD
TYNGSBORO, MASSACHUSETTS 01879-2199
TEL: (978) 454-5411 FAX: (978) 441-5344
www.gltech.org

Jill A. Davis
Interim Superintendent-Director

Michael R.H. Barton
Interim Assistant Superintendent/Principal

William J. Collins
Superintendent-Emeritus

SCHOOL COMMITTEE

Curtis J. LeMay
Chair
Paul E. Morin
Vice-Chair
Kempton P. Giggey
Secretary
Fred W. Bahou, Jr.
Lee Gitschier
George W. O'Hare
Matthew J. Sheehan
George A. Tatseos

ជូនចំពោះក្រុមគ្រួសារសាលាបច្ចេកទេសតំបន់ឡូវែល,

យើងយល់ថាគ្រួសារជាច្រើនមានសំណួរពាក់ព័ន្ធនឹងការផ្ទុះឡើងនៃវីរុសក្លូរ៉ូណា (2019-nCoV) ហើយតើវាអាចប៉ះពាល់ដល់សាលាសហគមន៍របស់យើងដោយរបៀបណា ។ មជ្ឈមណ្ឌលការពារ និងទប់ស្កាត់ជម្ងឺឆ្លង កំពុងតែផ្តល់ព័ត៌មានថ្មីៗ និង អនុសាសន៍ប្រចាំថ្ងៃ ។ សូមចុចលើការតភ្ជាប់ដូចតទៅនេះដើម្បីទទួលបានព័ត៌មានថ្មីៗ https://www.cdc.gov/coronavirus/2019-ncov/index.html ។ សូមមើលសន្លឹកព័ត៌មានបានភ្ជាប់ផ្នែកលើសំណួរដែលបានសួរជាញឹកញាប់ដែលបានបង្កើតឡើងដោយក្រសួងសុខភាពសាធារណៈរដ្ឋម៉ាស្សាឈ្យូសិត ។

ខណៈពេលនេះគឺជាការព្រួយបារម្ភពីសុខភាពសាធារណៈ, មជ្ឈមណ្ឌលការពារ និង ទប់ស្កាត់ជម្ងឺឆ្លងបន្តរាយការណ៍ថា ហានិភ័យភ្លាមៗចំពោះប្រជាជនទូទៅនៅតែមានកម្រិតទាបនៅពេលនេះ ។ ប៉ុន្តែនៅក្នុងពិភពលោកដែលមានទំនាក់ទំនងជាប់គ្នាសព្វថ្ងៃនេះ ដោយមានចំនួនគ្រួសារជាច្រើនធ្វើដំណើរក្នុងកំឡុងពេលសប្តាហ៍វិស្សមកាល សក្តានុពលនៃជម្ងឺឆ្លងគឺតែងតែជាក្តីព្រួយបារម្ភជានិច្ច ។ ដូចជាជម្ងឺគ្រុនផ្តាសាយធំ និង ជម្ងឺឆ្លងរលាកបំពង់ក ត្រូវមានការប្រុងប្រយ័ត្នជាទូទៅដែលយើងទាំងអស់គ្នាអាចអនុវត្តដើម្បីធ្វើឲ្យមានសុខភាពល្អតាមដែលអាចធ្វើទៅបាន ។

- អនុវត្តអនាម័យដៃឲ្យបានល្អ ។ លាងដៃជាញឹកញាប់ ហើយយ៉ាងហ្មត់ចត់ជាមួយសាប៊ូ និង ទឹកយ៉ាងហោចណាស់ 20 វិនាទី ។ ជៀសវាងយកដៃដែលមិនទាន់បានលាងស្អាតទៅប៉ះភ្នែក, ច្រមុះ និង មាត់របស់អ្នក ។ ប្រើអាល់កុលសម្រាប់លាងដៃនៅពេលគ្មានសាប៊ូ និង ទឹកលាងដៃ ។
- ន នៅពេលក្អក និង កណ្តាស់ ចូរខ្ទប់មាត់ និង ច្រមុះរបស់អ្នកជាមួយក្រដាសជូតស្តើងៗ ។ អ្នកក៏អាចក្អក ឬកណ្តាស់នៅក្នុងដៃអាវរបស់អ្នកបានដែរ ។ន បោះចោលក្រដាសជូតស្តើងៗនោះក្នុងធុងសំរាម ហើយលាងដៃរបស់អ្នកភ្លាមៗជាមួយសាប៊ូ និង ទឹកយ៉ាងហោចណាស់ 20 វិនាទី ។ន
- ន ជៀសវាងចែករំលែកកែវញ៉ាំទឹក, ពែង, សមស្លាបព្រា, ចាន, កូនកន្សែង ឬរបស់របរប្រើប្រាស់ផ្សេងទៀត ។ លាងរបស់របរទាំងនេះឲ្យបានស្អាតជាមួយនសាប៊ូ និង ទឹកបន្ទាប់ពីប្រើវា ។ន
- ន ជៀសសវាងនៅជិតមនុស្សដែលឈឺពេលណាដែលអាចធ្វើទៅបាន ។ន
- អនុវត្តទម្លាប់ដែលធ្វើឲ្យមានសុខភាពល្អផ្សេងទៀត៖ សំអាត និង រម្ងាប់មេរោគលើផ្ទៃកន្លែងដែលប៉ះនៅផ្ទះ, កន្លែងធ្វើការ ឬសាលាជាញឹកញាប់ ជាពិសេសននៅពេលមានអ្នកណាម្នាក់ឈឺ ។ គេងឲ្យបានច្រើន, ធ្វើឲ្យរាងកាយសកម្ម, គ្រប់គ្រងភាពតានតឹងរបស់អ្នក, ញ៉ាំទឹកឲ្យបានច្រើន ហើយញ៉ាំអាហារដែលមានជីវជាតិ ។

វាជារឿងដ៏សំខាន់ក្នុងការឲ្យក្មេងនៅផ្ទះដោយមិនឲ្យទៅសាលារៀននៅពេលពួកគេឈឺ ។ ប្រសិនបើក្មេងមានរោគសញ្ញាណាមួយនៃរោគសញ្ញាដូចមានតទៅនេះ សូមឲ្យពួកគេនៅផ្ទះ៖ មានកំដៅខ្ពស់ជាង 100.4 អង្សា, ក្អួត, ក្អួត, រាគរូស, ចេញកន្ទួលដែលមិនទាន់ត្រូវបានធ្វើរោគវិនិច្ឆ័យដោយវេជ្ជបណ្ឌិត, ភ្នែករមាស់ឡើងក្រហម ឬផ្តាឈូក, និង/ឬ ហូរទឹកភ្នែក ហើយមានជម្ងឺឆ្លងណាមួយដូចជា អុតស្វាយ, រលាកបំពង់ក ឬជម្ងឺគ្រុនផ្តាសាយធំជាដើម

វីរុសក្លូរ៉ូណា (2019-nCoV) គឺជាស្ថានភាពវិវឌ្ឍន៍ដែលយើងកំពុងតែតាមដានយ៉ាងយកចិត្តទុកដាក់ ហើយនឹងបន្តផ្តល់បច្ចុប្បន្នភាពដល់អ្នក ពេលព័ត៌មានត្រូវបានគេចែករំលែកជាមួយនឹងយើង ។ សូមធានាថា យើងកំពុងតែតាមដាននូវក្តីព្រួយបារម្ភពីសុខភាពរបស់សិស្ស ។ យើងកំពុងតែប្រាស្រ័យទាក់ទងយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាសុខភាពមូលដ្ឋាន, ក្រសួងសុខភាពសាធារណៈរដ្ឋម៉ាស្សាឈូសិត/ផ្នែកសុខភាពប្រចាំសាលា ក៏ដូចអ្នកផ្តល់សេវាថែទាំសុខភាពនៅក្នុងសហគមន៍ ។ ផ្នែកគ្រប់គ្រងអាគារសាលារបស់យើងកំពុងតែធ្វើឲ្យមានអនាម័យនៅកន្លែងសិក្សារបស់យើង ដូចដែលយើងធ្វើជាធម្មតាក្នុងរដូវគ្រុនផ្តាសាយ និង គ្រុនផ្តាសាយធំអញ្ចឹងដែរ ។ យើងកំពុងតែធ្វើតាមគោលការណ៍ណែនាំទាំងអស់ដើម្បីធានាសុវត្ថិភាពរបស់សិស្ស និង បុគ្គលិករបស់យើង ។ យើងនៅតែប្តេជ្ញាចិត្តយ៉ាងខ្លាំងចំពោះភាពសុខសប្បាយរបស់សិស្ស និង បុគ្គលិក ហើយនឹងបន្តចែករំលែកព័ត៌មានថ្មីៗដែលចាំបាច់ជាមួយអ្នកអំពីស្ថានភាពកំពុងវិវឌ្ឍន៍នេះ ។

ដោយក្តីគោរពរាប់អាន,